**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ការិយាល័យអ្នកនាំពាក្យ**

## សេចក្តីបដិសេធ

ការិយាល័យអ្នកនាំពាក្យ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជនជ្រាបថា មានជនខិលខូចបានក្លែងបន្លំសេចក្តីជូនដំណឹងរបស់ក្រសួង ក្នុងគោលបំណងទុច្ចរិត បោកប្រាស់សាធារណជន ជាពិសេស បុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស ឱ្យបង់ថ្លៃសេវាតាមរយៈលេខគណនីដែលមាននៅក្នុងសេចក្តីជូនដំណឹង និងដោយប្រើប្រាស់ឈ្មោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាភាសាអង់គ្លេស (Ministry of Labor and Vocational Training)។

ការិយាល័យអ្នកនាំពាក្យ សូមបដិសេធទាំងស្រុងចំពោះ សេចក្តីប្រកាសជូនដំណឹងគ្មានលេខ ចុះថ្ងៃច័ន្ទ ១១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ ស្តីពីការបង់ថ្លៃសេវាគ្រប់ទាំងអស់ ដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹងខាងលើ ដែលបានបង្ហោះក្នុងក្រុមតេឡេក្រាម "**សម្រាប់និយោជក**" (https://t.me/EmployerChat) ដោយប្រើប្រាស់គណនីធនាគារឈ្មោះ (Ministry of Labor and Vocational Training) និងលេខគណនី 855762224592 សម្រាប់បង់ប្រាក់។

ទន្ទឹមនេះ ការិយាល័យអ្នកនាំពាក្យ សូមអំពាវនាវដល់សាធារណជន ជាពិសេស បុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស គ្រឹះស្ថាន ត្រូវប្រុងប្រយ័ត្នខ្ពស់ចំពោះការក្លែងបន្លំគ្រប់រូបភាពរបស់ជនខិលខូច។ ក្រសួងសូមថ្កោលទោសទង្វើបំពានច្បាប់របស់ជនខិលខូចនេះ និងសូមប្រមានឱ្យបញ្ឈប់នូវទង្វើរបស់ខ្លួនជាបន្ទាន់។ ជាក់ស្តែង ក្រសួងមិនមានគោលការណ៍ឱ្យមន្ត្រីណាម្នាក់បង្កើតគណនីធនាគារផ្ទាល់ខ្លួន ដើម្បីទទួលប្រាក់នោះទេ។ បច្ចុប្បន្ន ក្រសួងកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចស្វែងរកអត្តសញ្ញាណជនល្មើស ដើម្បីផ្តន្ទាទោសតាមច្បាប់។

ក្នុងករណីសាធារណជន មានការសង្ស័យណាមួយ ឬសួរនាំព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" ឬ ក្រុមតេឡេក្រាមផ្លូវការ "**សម្រាប់ និយោជក**" (https://t.me/EmployerChat) ឬប្រអប់បណ្តឹងអនាមិករបស់ក្រសួង (https://feedback.mlvt.gov.kh/feedback)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស គ្រឹះស្ថាន និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសូមបង្កើនការប្រុងប្រយ័ត្នចំពោះករណីឆបោកក្លែងបន្លំនេះ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៥

"សម្រាប់និយោជក" "បណ្តឹងអនាមិក"

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩